មាត្រា ៥ .-

ការលុបឈ្មោះចេញពីក្របខ័ណ្ឌ ការដាក់អោយចូលនិវត្តន៍ និងការលុបឈ្មោះចេញពីតារាងបៀវត្ស ចំពោះមន្ត្រី បុគ្គលិក រាជការស៊ីវិល ដែលមានចែងក្នុងមាត្រា ១-២-៣ និង ៤ ត្រូវអនុវត្តអោយបាន ត្រឹមត្រូវតាមច្បាប់ និងស្របទៅតាមនីតិវិធី ជាធរមាន ហើយត្រូវជំរះចេញអោយអស់ពីតារាងបៀវត្ស ចាប់ពីខែកញ្ញា ឆ្នាំ២០០០ តទៅ ។

មាត្រា ៦ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែល ពាក់ព័ន្ធ អភិបាលគ្រប់ខេត្ត-ក្រុង និងមន្ត្រី បុគ្គលិក រាជការ ស៊ីវិល ដែលមានឈ្មោះចែងក្នុង ឧបសម្ព័ន្ធ ទី១ ទី២ ទី៣ និងទី៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ហត្ថលេខា

សុខ អាន

***

អនុក្រឹត្យ លេខ ៥៤ អនក្រ.បក

ស្តីពី

ការកែតម្រូវអនុក្រឹត្យលេខ ២៣ អនក្រ.បក ស្តីពីការអភិវឌ្ឍន៍តំបន់កំពង់ផែស្វយ័ត ក្រុងព្រះសីហនុ

***

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.ប៉ក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើត កំពង់ផែស្វយ័តក្រុងព្រះសីហនុ

www.pheakdeylaw.com

-បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០០ ស្តីពីការអភិវឌ្ឍន៍តំបន់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សំរេច

មាត្រា ១ .- មាត្រា២ នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០០០ ត្រូវបានកែតំរូវដូចខាងក្រោម :

មាត្រាថ្មី២ : ចាត់ទុកជាមោឃៈ នូវប័ណ្ណសំគាល់សិទ្ធិលេខ A_3 0508, A_3 0048, A_3 0455, A_3 0067, A_3 0509, A_3 0615, A_3 0512, A_{III} 0260, A_{III} 0330, A_{III} 0210, A_{III} 0211, A_{III} 0240, A_{III} 0002, A_{III} 0003, A_I 0037, A_I 0176, A_I 0003, A_I 0789, A_3 0682, A_3 0674, A_3 0031 និងឯកសារទាំងឡាយណាដែលពាក់ព័ន្ធនឹងការផ្តល់សិទ្ធិកាន់កាប់ដីធ្លី ស្ថិតនៅក្នុងតំបន់ដូចមានចែងនៅក្នុងមាត្រា១ ដោយប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់រដ្ឋ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អភិបាលក្រុងព្រះសីហនុ កំពង់ផែស្វយ័តក្រុងព្រះសីហនុ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋដែលមានដីស្ថិតនៅក្នុងបរិវេណដូចបានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

អនុក្រឹត្យ លេខ ៥៥ អនក្រ.បក
ស្តីពី ការផ្ទេរសេណានាធិការ

***

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

www.pheakdeylaw.com